# សិលាចារឹកប្រាសាទប្រាំ ខេត្តក្រចេះ (K.1431)

សិលាចារឹកនេះ រកឃើញនៅបរិវេណប្រាសាទប្រាំ ភូមិកសាង ឃុំចង្ក្រង់ ស្រុកចិត្របុរី ខេត្តក្រចេះ និងបានយកមករក្សាទុកនៅវត្តកសាងនៅឆ្នាំ២០០៣។ ក្រោយមក នៅរវាងឆ្នាំ២០០៦ សិលាចារឹកនេះបានបាត់ពីវត្តកសាង រហូតមិនមានដំណឹងមកទល់បច្ចុប្បន្ន។ កាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ លោក **ហ៊ិន ឈុនតេង** បានសិក្សាផ្នែកអត្ថបទជាភាសាខ្មែរនៃសិលាចារឹកនេះម្តងរួចមកហើយ ដោយយោងទៅលើសំណៅផ្តិត ដែលគេកំពុងរក្សាទុកនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តក្រចេះ។ ទោះបីជាយ៉ាងណា ផ្នែកអត្ថបទជាភាសាសំស្រ្កឹត លោកពុំទាន់បានសិក្សានៅឡើយ។ ហេតុដូច្នេះហើយ នៅក្នុងអត្ថបទនេះ យើងនឹងលើកយកផ្នែកភាសាសំស្រ្កឹតមកសិក្សា។

សិលាចារឹកនេះ ជាប្រភេទថ្មគោលមានចារឹកអក្សរសងខាង។ ផ្នែកទី១ ជាភាសាសំស្រ្កឹត មានចំនួន ២២ បន្ទាត់ និងផ្នែកទី២ជាភាសាខ្មែរមានចំនួន ១៨ បន្ទាត់។ ផ្នែកទី២ មានបញ្ជាក់កាលបរិច្ឆេទដាក់លាក់នៅមហាសករាជឆ្នាំ៦០៨ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៦៨៦ ដែលរៀបរាប់អំពីព្រះរាជអាជ្ញារបស់ព្រះបាទស្រីជយវម៌្ម(ទី១)។ កាលបរិច្ឆេទនេះ ពិតជាមានសារសំខាន់ណាស់ ព្រោះវាផ្ទុយទៅនឹងការកំណត់កាលបរិច្ឆេទរបស់ប្រវត្តិវិទូមុនៗ ដែលកំណត់ថា ព្រះបាទស្រីជយវម៌្មទី១ ឡើងសោយរាជ្យនៅគ.ស.៦៥៧ ដល់ ៦៨១។

ចំពោះខ្លឹមសារជារួមនៃអត្ថបទជាភាសាសំស្រ្កឹត របស់សិលាចារឹកនេះ រៀបរាប់អំពី៖

- ស្លោកទី១ ពណ៌នាអំពីព្រះសិវ
- ស្លោកទី២ ពណ៌នាអំពីរាជវង្សព្រះមហាក្សត្រក្នុងត្រកូលសោមវង្ស
- ស្លោកទី៣ ពណ៌នាអំពីសេចក្តីព្យាយាម និងគុណធម៌របស់ព្រះមហាក្សត្រ
- ស្លោកទី៤ ពណ៌នាអំពីព្រះរាជអាជ្ញារបស់ព្រះមហាក្សត្រ ដើម្បីកសាងអាពមទីសក្ការបូជាព្រះមហេស្វរ
- ស្លោកទី៥ ទី៦ ពណ៌នាអំពីព្រះបាទគ្រីជយវម៌ទី១ និងគុណសម្បត្តិ និងរាជអាជ្ញា
- ស្លោកទី៧ ពណ៌នាអំពីដ្ឋានចន្ទ្រ

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់

- *ស្លោកទី៨ ទី៩ ពណ៌នាអំពីព្រះរាជអាជ្ញារបស់ព្រះមហាក្សត្រ*
- *ស្លោកទី១០ ពណ៌នាអំពីពាក្យបណ្តាសា*
- *ស្លោកទី១១ ពណ៌នាអំពីឆ្នាំចារឹក។*

## អត្ថបទចារឹក និងសេចក្តីប្រែ

១. ជយតី ន្ទ្រាទិទេវាស្យ ក្រ្តិមាន្យជ្ជបតីគ្វរះ
ជិតស្វ្រាន្ងៃយ៉្យស្ស្បាធុ- តាប៉្បីតោកុវិយជ្វកិះ។

***ប្រែថា៖*** *ព្រះយជ្ជបតីគួរដ៏មានសិរីតែងតែឈ្នះ ទ្រង់ជាប្រមុខនៃពួកទេព្តាទាំងពួង មានព្រះឥន្ទ្រជាអាទិ៍ ទ្រង់បានឈ្នះហើយដោយអាជ្ញាដ៏ត្រឹមត្រូវ ប្រកបដោយសប្បុរសភាព ទ្រង់ត្រូវបានបូជាថ្វាយដោយពិធីបូជាយញ្ញទាំងឡាយជាច្រើនលើលោក។*

### ជ្រុងទី១

១. ជយត្យជោភវោភូត- ភាវជោភគវាន្ធិភុះ
ប្រិភុវេកោន្តទុរ៉ោជ- មហិមាជគជីត្វរះ។

***ប្រែថា៖*** *(ព្រះសិវ)តែងតែឈ្នះ ទ្រង់ជាព្រះអជៈ ជាព្រះភព ជាព្រះភូតភាវនៈ ជាព្រះភគវ័តជាព្រះវិភូ ជាព្រះប្រភុ ជាសភាវៈដ៏មហិមាដែលយល់បានដោយកម្របំផុត និង ជាព្រះជគទីគ្វរៈ។*

២. អស្តិ សោមាន្វយឆកសិ សំបូណ្ណ៌ាន្ទបតីតកុះ
កុណាន្ត៌ុវីវ៉ោន្ទាម- កាមុជាហ្វាឧជោឧយះ។

***ប្រែថា៖*** *មានព្រះរាជាមួយព្រះអង្គជាកំពូលពូជដ៏សោមវង្ស ជាអាវុធដ៏ត្រជាក់លើអធិបតេយ្យភាពដែនដីដ៏បរិបូណ៌ មានគុណដ៏សន្ធឹកដូចមហាសាគរ ជាទីឧទ័យឡើងនៃភាពរីករាយដូចជាបណ្តុំនៃផ្កាឈូកស។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

៣. គមិតាយោជនាធ្វាន- មិបុណា ភាហុវីយ៌្យតះ
ក្សេ្រ្ត្រកលិមលាលេប- ក្ឃ្យាលនាធិវន្ទ្វរតះ។

***ប្រែថា៖*** *ទ្រង់បានយាងធ្វើដំណើរទៅអស់ចម្ងាយនៃយោជន៍ ប្រកបដោយវិរិយភាពដ៏លើសលប់តាំងតែពីចម្ងាយ ព្រោះតែដើម្បីលាងជម្រះនូវការប្រលាក់ដ៏សៅហ្មងនៅក្នុងកលិយុគដោយពួកក្សត្រទាំងឡាយជាអាទិ៍។*

៤. [ជេ]ពោ៌ច្យុតមហោគាជា- ធ្យមរស្ថានជាមភិះ
គាលាត្រមៃះ បុរំ ភជា ត្រិវិម្តបមិភាគភោតិ។

***ប្រែថា៖*** *ព្រះរាជាទ្រង់បានបញ្ជាឱ្យគេកសាងនូវបុរី ដែលប្រៀបដូចនឹង**ត្រិវិម្តប*** *(គឺស្ថានសួគ៌) ព្រមទាំងសាលា និងអាស្រមទាំងឡាយ ដែលហាក់បីដូចជាអមរស្ថានដ៏មានជោគនៃព្រះមហេសូរជាអម្រឹតជាអាទិ៍។*

៥. ត្រីមានត្រីជយវម្ម៌ាតិ គព្រោបេន្ទ្របរាក្រមះ
ដ្ឋចោភូត្តមិភាជ្យាំគ- មស្តកន្យស្តតាសនះ។

***ប្រែថា៖*** *ព្រះរាជាអង្គនេះ មានព្រះនាមថា**ត្រីជយវម៌**ដ៏មានសិរី ទ្រង់ខ្លាំងក្លាប្រៀបបាននឹងស្តេចសក្រទេវេន្ទ្រាធិរាជ ទ្រង់មានព្រះរាជសាសន៍ (គឺព្រះរាជបញ្ជា) ត្រូវបានលើកទ្រលើសិរសាដោយពួកព្រះនរបតីទាំងឡាយដែលមាន**ភូមិរាជ្យាង្គ*** *(គឺដែនរាជ្យដែលប្រកបដោយអង្គ ៧ ឬ ៩ ប្រការ)។*

៦. តស្យាជ្ញយាសនាបុណ្យំ ធេវតាលាត្រមេមុយតិ
សំហាជិតំប្រែសិទ្ធន្តតិ យជ្ជូភិវិសុសវៃតះ។

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

***ប្រែថា៖*** *ព្រោះព្រះរាជអាជ្ញារបស់ព្រះអង្គ ជារៀងរាល់ថ្ងៃបុណ្យណា[បានធ្វើ]ក្នុងអាស្រម និងសាលាទាំងឡាយនៃទេវាល័យហើយ បុណ្យនោះនឹងត្រូវបានសម្រេចផលដោយគ្មានការរាំងស្ទះ ដោយការបូជាយញ្ញទាំងឡាយ និងសម្បត្តិមកពីគ្រប់ទិសទី។*

៧. វិមុក្តបត្តនគ្រាមេ ជ្វានចន្ទ្រែនយជ្វនា
បុហ្វាគ្រមេជនំឧត្តមិ ក្សេត្រភ្ឫត្យគវាឌិយតិ។

***ប្រែថា៖*** *តាមរយៈលោកបូជាចារ្យជ្វានចន្ទ្រព្ធដ៏វិមុក្តបត្តនគ្រាម ទ្រព្យធនដែលត្រូវបាន ថ្វាយហើយក្នុងបុហ្វាស្រម គឺមានដីស្រែ ខ្ញុំបម្រើ និងគោទាំងឡាយជាអាទិ៍។*

៨. តត្រែតរំ ប្រធានត្ន យច្ចបុណ្យម្បមាគ្រិតមិ
អចាលិនិយមិត្យេហ ឆ្ឫចាជ្វាសវ៌ធាឆ្ឫកិះ។

***ប្រែថា៖*** *ទ្រព្យធនដទៃទៀតដែលប្រទានទុកក្នុងទីនេះក្តី ត្រូវបានការពារទុកដើម្បីចម្រើន បុណ្យ មិនត្រូវឱ្យពួកមនុស្សរុះរើក្នុងទីនេះឡើយ នេះគឺជាព្រះរាជអាជ្ញាឮដ៏គ្រប់សម័យកាល។*

៩. ត្រាទ្ធ្យយយុក្តាធាំ យោគិធាមត្រ សវ៌ធា
កុត្តិរាគ្រមសនិត្តា- ធ្យហាយ៌្យានិវលានិតះ។

***ប្រែថា៖*** *មិនត្រូវគ្រប់គ្រងផ្តាច់មុខ ឬលួច ឬយកទៅទីដទៃ ឬថាដុតបំផ្លាញនូវអាស្រម សម្រាប់ប្រើប្រាស់របស់**ព្រះយោគី**ទាំងឡាយដែលកំពុងចំណាយពេលក្នុងការបំពេញ**ព្រត**ក្នុងទីនេះគ្រប់ពេលទាំងពួងឡើយ។*

១០. ឆ្ឫចាជ្វាលដ្ឋិយឥកុ បិណ្ឌិតាស្តេ៍បិ ពោមតះ
គច្ឆន្តិ នរកានិប្រែត្យ- ភេវរានិនតេ បតាះ។

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

***ប្រែថា៖*** *ជនទាំងឡាយណាល្មើសនូវព្រះរាជអាជ្ញាទោះបីត្រូវបានសរុបកាត់ក្តីពីទោសហើយក្តី ក៏បន្ទាប់ពីស្លាប់ទៅជនទាំងឡាយនោះរមែងទៅធ្លាក់កាន់នរកទាំងឡាយ ៧ ប្រភេទមាន* ***រៅរវ****ៈជាអាទិ៍។*

១១. --វេជាម្ពសហិតេ ឞរក្បេ្យតការត្សេរ
រចិតាប្រែឝម្ពលេខា តិម្ពន្ធ្វាភូតសំប្វាតិ។

***ប្រែថា៖*** *ក្នុងសកសំវច្ឆរៈទី៦០៨..... សិលាចារឹកទាំងឡាយត្រូវបានចារឹកចារ ឡើង(នេះ) សូមឱ្យតាំងនៅជរាបលោកវិនាស។*

*ជារួមមក សិលាចារឹកប្រាសាទប្រាំ* (K.1431) *បានផ្តល់ព័ត៌មានជាច្រើនអំពីគុណសម្បត្តិព្រះរាជអាជ្ញា និងព្រឹត្តិការណ៍ទូទៅនៅក្នុងរជ្ជកាលព្រះបាទស្រីជយវម៌្មទី១ នៅក្នុងមហាសករាជឆ្នាំ ៦០៨ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៦៨៦ ដែលបញ្ជាក់យ៉ាងច្បាស់ថារជ្ជកាលរបស់ទ្រង់មិនទាន់បញ្ចប់នៅឡើយទេនៅក្នុងគ.ស.៦៨១ ដូចដែលប្រវត្តិវិទូមុនៗបានស្នើឡើង។*

អរិយធម៌ខ្មែរ KHMER CIVILIZATION



រូបលេខ១៖ ប្រាសាទប្រាំ ស្រុកចិត្របុរី ខេត្តក្រចេះ



រូបលេខ២៖ ប្រាសាទប្រាំ ស្រុកចិត្របុរី ខេត្តក្រចេះ

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគន្ធ



រូបលេខ៣៖ សំណៅផ្តិតសិលាចារឹកប្រាសាទប្រាំ ផ្នែកភាសាសំស្ក្រឹត
(ប្រភព៖ មិនស្គាល់ម្ចាស់សំណៅ តែរក្សាទុកមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តក្រចេះ)

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់



*រូបលេខ២៤៖ សំណៅផ្តិតសិលាចារឹកប្រាសាទប្រាំ ផ្នែកភាសាខ្មែរ*
*(ប្រភព៖ មិនស្គាល់ម្ចាស់សំណៅ តែរក្សាទុកមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តក្រចេះ)*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*